**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
លេខ: ០៥៤/២១ អររ

## សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពីលទ្ធផលនៃសន្និសីទសារព័ត៌មាន ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១

ព្រឹកថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្ដីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្តរបស់ខេត្តកំពត»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ញ៉េម សាឯម សមាជិកក្រុមប្រឹក្សាខេត្តកំពត**
- **ឯកឧត្តម អ៊ឹម នាយ អភិបាលរង នៃគណៈអភិបាលខេត្តកំពត**
- **លោក ស៊ុម យុត ចៅសង្កាត់ក្រាំងអំពិល ក្រុងកំពត**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីយន្តការប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាប្រវត្តិសាស្ត្រកម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍន៍មូលដ្ឋានឃុំ-សង្កាត់។

## I. សេចក្ដីផ្ដើម

ខេត្តកំពត គឺជាខេត្តមួយដែលមានអំណោយផលពីធនធានធម្មជាតិ សម្រាប់ការអភិវឌ្ឍលើវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ ដែលវិស័យសក្ដានុពលរបស់ខេត្តមាន អំបិល ពោងចក្រស៊ីម៉ង់ត៍ វារីអគ្គិសនី កសិកម្ម នេសាទសមុទ្រ ទេសចរណ៍ និងមានឆ្នេរសមុទ្រប្រវែងសរុប ៦៦,៥ គ.ម។

## II. វឌ្ឍនភាពការងារ

វឌ្ឍនភាពការងារដែលខេត្តសម្រេចបានរួមមាន៖

❖ **ក្រុមប្រឹក្សាខេត្ត**

- ការងារអភិវឌ្ឍន៍៖ ក្រុមហ៊ុនមកធ្វើការវិនិយោគនៅខេត្តកំពតមានចំនួន ៣៥ ក្រុមហ៊ុន ក្នុងនោះ ក្រុមហ៊ុនវិនិយោគវិស័យកសិ-ឧស្សាហកម្ម ចំនួន០៤ កំពង់ផែខ្នាតតូច ចំនួន០៥ ឧស្សាហកម្ម ចំនួន០៩ ទេសចរណ៍-សណ្ឋាគារចំនួន ១០ រោងចក្រចំនួន ០១ ថាមពលចំនួន ០៣ តំបន់សេដ្ឋកិច្ច ពិសេសចំនួន ០២ ផលិតនិងកែច្នៃផលិតផលសមុទ្រចំនួន ០១។ ចំពោះ ឧស្សាហកម្មធុនធំ ២៤មូលដ្ឋាន សហគ្រាសធុនតូច និងមធ្យម ៤៩មូលដ្ឋាន សិប្បកម្មសរុប ២.៨១៤មូលដ្ឋាន។
- ការងារសង្គមកិច្ច៖ បានឧបត្ថម្ភសាច់ប្រាក់ដល់ជនក្រីក្រ កុមារអាយុក្រោម២ឆ្នាំ និងស្ត្រីមានផ្ទៃពោះ និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជាពិសេស ជនក្រីក្រក្នុងដំណាក់កាល កូវីដ១៩។ ក្នុងនោះគិតត្រឹមថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ សរុបបានចំនួន ៧.១៨៥គ្រួសារ ក្រ១(៣.៧៥៥ គ្រួសារ) ក្រ២(៣.៤៣០គ្រួសារ)។ គិតត្រឹមថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ មានចំនួន ២៥.៦៩១ គ្រួសារ ដោយគិតជាថវិកាឧបត្ថម្ភដល់ជនងាយរងគ្រោះប្រភេទ១ និងប្រភេទ២ សរុបស្មើនឹង ២៤.៣៩៦.៧៦៤.០០០ រៀល។ ចំពោះស្ត្រីមានផ្ទៃពោះនៅក្នុងគ្រួសារក្រីក្រ ទទួលបានប្រាក់ ឧបត្ថម្ភពីកម្មវិធីគាំទ្រការពារ ស្ត្រីមានផ្ទៃពោះ ចំនួន ១.៨៧៣នាក់ និងកុមារតូចមានចំនួន ៦៣៩នាក់ ដោយទទួលបានឧបត្ថម្ភគិតជាថវិកាសរុបចំនួន ៧៥៥.៩៦០.០០០រៀល។
- ការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីត-១៩៖ បានរៀបចំកិច្ចប្រជុំតាមរយៈអនឡាញ និងផ្ទាល់ ជាមួយបណ្ដាក្រុង ស្រុក មន្ទីរ អង្គភាព ក្នុងការដាក់ចេញនូវវិធានការ និងផែនការសកម្មភាពក្នុង ការទប់ស្កាត់នឹងជំងឺកូវីដ១៩ និងផ្ដល់សម្ភារបរិក្ខាពេទ្យ គ្រឿងឧបភោគ-បរិភោគ ចែកខិតប័ណ្ណ និងផ្ទាំងរូបភាពផ្សព្វផ្សាយដល់រដ្ឋបាលក្រុង-ស្រុក ដែលជាវិធានការឆ្លើយតបក្នុងការទប់ ស្កាត់ស្ថានភាព ជំងឺកូវីដ-១៩ កុំឱ្យមានការរីករាលដាលចូលសហគមន៍ និងបានត្រៀមកន្លែងធ្វើ ចត្តាឡីស័ក និងមន្ទីរពេទ្យសម្រាប់ព្យាបាល និងទទួលពលករត្រឡប់មកក្នុង និងក្រៅប្រទេស ទូទាំងខេត្តមានចំនួន ០៧កន្លែង ស្មើនឹង១៥០បន្ទប់ និងតាមបណ្ដាក្រុង ស្រុក ដូចជា មណ្ឌលសុខភាព សាលារៀន ក្នុងរាជរដ្ឋាភិបាលបានឧបត្ថម្ភថវិកា ៣០ លានរៀល សម្រាប់ ការងារចត្តាឡីស័ក។

- ❖ **សង្កាត់ក្រាំងអំពិល**

- ផ្នែកហេដ្ឋារចនាសម្ព័ន្ធ៖ មានផ្លូវបេតុង កៅស៊ូ គ្រួសក្រហម ដោយបានប្រើប្រាស់ថវិការាជរដ្ឋាភិបាល និងការគៀងគរពី សប្បុរជនបានកសាងផ្លូវចំនួន២០ខ្សែ ប្រវែងសរុប ២,៤០៣៦ម៉ែត្រ អមដោយប្រពន្ធ័លូ
- វិស័យកសិកម្ម៖ សង្កាត់ក្រាំងអំពិលមានផ្ទៃដីកសិកម្ម សម្រាប់បង្កបង្កើនផលសរុប ៦៥ហិកតា និងមានការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារដូចជា គោ ជ្រូក មាន់ ទាជាដើម
- វិស័យសង្គមកិច្ច៖ បានអនុវត្តគោលនយោបាយគាំពារសង្គមដោយបានឧបត្ថម្ភសាច់ប្រាក់ដល់ជនក្រីក្រ កុមារក្រោមអាយុ២ឆ្នាំ ស្ត្រីមានផ្ទៃពោះ និងបានបង្កើតសមាគមន៍មនុស្សចាស់ ក្នុងគោលបំណងដើម្បីជួយគ្នាក្នុងពេលមានការឈឺស្កាត់និងមរណៈភាព
- ការងារសន្តិសុខ និងសណ្តាប់ធ្នាប់៖ បានអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ដោយបានរៀបចំធ្វើវេទិកាសាធារណៈស្តីពីតម្រូវការ និងសំណូមពររបស់ប្រជាពលរដ្ឋជារៀងរាល់ខែ ចុះសួរសុខទុកតាមខ្នងផ្ទះ និងចុះផ្សព្វផ្សាយពីកាការពារខ្លួនពីជំងឺកូវីដ១៩

## III. ទិសដៅការងារបន្ត

- ❖ **ក្រុមប្រឹក្សាខេត្ត**

- បន្តធ្វើវេទិកាសាធារណៈនៅតាមភូមិ ឃុំ សង្កាត់ ក្នុងក្រុង ស្រុក ទូទាំងខេត្ត ឱ្យបានជាប់ជាប្រចាំ និងទៀងទាត់
- បន្តពិនិត្យករណីសំណូមពររបស់ប្រជាពលរដ្ឋ ដែលនៅសេសសល់មិនទាន់ដោះស្រាយ ដើម្បីស្វែងរកដំណោះស្រាយទៅតាមស្ថានភាព និងលទ្ធភាពជាក់ស្តែង
- បន្តចូលរួមអប់រំ ណែនាំប្រជាពលរដ្ឋ អំពីការអនុវត្តដោយប្រុងប្រយ័ត្ននូវវិធានការការពារ និងទប់ស្កាត់ ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ចូលរួមអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល ក្នុងផែនការស្តារ និងអភិវឌ្ឍសេដ្ឋកិច្ចសង្គមឡើងវិញនៅក្រោយដំណាក់កាលវិបត្តិកូវីដ-១៩ ជាពិសេស ការបន្តការទាក់ទាញវិនិយោគ ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម កសិកម្ម ទេសចរណ៍ និងការស្តារ ពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា
- ចូលរួមជំរុញការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល និងគម្រោងអភិវឌ្ឍន៍របស់មូលដ្ឋានក្រុង-ស្រុក ឃុំ សង្កាត់ ឱ្យសម្រេចបានលទ្ធផលល្អប្រសើរ និងលើកកម្ពស់ការផ្តល់សេវាសាធារណៈ

- លើកទឹកចិត្តចំពោះអ្នកវិនិយោគក្នុង និងក្រៅប្រទេស ឬស្វែងរកសប្បុរសជន អង្គការដៃគូអភិវឌ្ឍន៍នានា ដើម្បីជួយអភិវឌ្ឍន៍នៅតាមមូលដ្ឋាន និងបង្កើតការងារជូនប្រជាពលរដ្ឋ។

❖ **សង្កាត់ក្រាំងអំពិល ក្រុងកំពត៖**

- បន្តការយកចិត្តទុកដាក់ បំរើសេវារដ្ឋបាលជូន ប្រជាពលរដ្ឋអោយទាន់ពេលវេលា
- ផ្សព្វផ្សាយពីការបំរើសេវាសាធារណៈ និងសេវាសំណូមពរ ជូនដល់ប្រជាពលរដ្ឋឱ្យបានគ្រប់ៗគ្នា និងមានតម្លាភាព
- បន្តិការខិតខំពង្រឹងការអនុវត្តគោលនយោបាយ ភូមិ ឃុំ សុវត្ថិភាព ឱ្យកាន់តែល្អបន្ថែមទៀត
- បន្តការឆ្លើយតបការសំណូមពរបងប្អូនប្រជាពលរដ្ឋ ដែលបានលើកឡើងក្នុងវេទិកាសាធារណៈ
- បន្តការអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ពន្ធ័ ផ្លូវ លូ ដែលជាអាទិភាពចាំបាច់របស់រដ្ឋបាលសង្កាត់
- បន្តការផ្សព្វផ្សាយ គៀងគរ រកសប្បុរជន ដើម្បីចូលរួមអភិវឌ្ឍន៍នៅក្នុងមូលដ្ឋាន
- ជំរុញការធ្វើផែនការកម្មវិធីវិនិយោគឱ្យបានទាន់ពេលវេលា
- បន្តការយកចិត្តទុកដាក់ត្រួតពិនិត្យតាមដានការអនុវត្តន្តវកម្មវិធិឧបត្ថម្ភសាច់ប្រាក់ជូនប្រជាពលរដ្ឋ និងដោះស្រាយអោយទាន់ពេលវេលានៅពេលដែលបងប្អូនប្រជាពលរដ្ឋដកប្រាក់មិនបាន។

## IV. សម្គាល់

ចំពោះសកម្មភាពសេដ្ឋកិច្ច សង្គមកិច្ចនៅខេត្តកំពត សង្កេតឃើញថានៅរក្សាបានប្រក្រតីភាពនិរន្តភាព និងស្ថិរភាព ជាធម្មតា ទោះបីជាក្នុងកាលៈទេសៈ ប្រឈមនឹងការឆ្លងជំងឺកូវីដ១៩ ដោយជាក់ស្តែងរោងចក្រ សហគ្រាសនៅដំណើការធម្មតា ចំណែកភ្ញៀវទេសចរណ៍នៅតែមានការកើនឡើង ចំណូលពន្ធដារនៅរក្សាបានកំណើន។ កត្តាទាំងនេះហើយដែលធ្វើឲ្យខេត្ត ពុំចាំបាច់ធ្វើការចំណាយឧបត្ថម្ភលើកម្មកររោងចក្រ និងបុគ្គលិកផ្នែកសេវាកម្មទេសចរណ៍។ ក្រៅពីនេះដំណើការផលិតអំបិល នៅប្រព្រឹត្តទៅជាធម្មតា ដែលផ្នែកនេះក៏ជួយស្រូបយកកំលាំងពលកម្មមួយភាគដែរក្នុងខេត្ត។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១